ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គណៈកម្មាធិការលទ្ធកម្ម

លេខ ១៧៧.../២៤ គល

## សេចក្តីជូនដំណឹង

ស្តីពី

### ការអញ្ជើញចូលរួមដេញថ្លៃស្តីពីការងារជួសជុលទ្រុងសត្វនិងការងារអនាម័យជើងព្រៃនៅឧទ្យានសួនសត្វព្រៃ ការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" និងការងារជួសជុលក្លោងទ្វារ និងរបងថ្នាលបណ្តុះកូនឈើបែកចាន ប្រចាំឆ្នាំ២០២៤ របស់រដ្ឋបាលព្រៃឈើ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការអនុវត្តការងារជួសជុលទ្រុងសត្វនិងការងារអនាម័យជើងព្រៃនៅឧទ្យានសួនសត្វព្រៃ ការពារ និងសួនរុក្ខជាតិ "ភ្នំតាម៉ៅ" និងការងារជួសជុលក្លោងទ្វារ និងរបងថ្នាលបណ្តុះកូនឈើបែកចាន ប្រចាំឆ្នាំ២០២៤ របស់រដ្ឋបាលព្រៃឈើ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអាសយដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី.១៩.........ខែកក្កដា..ឆ្នាំ២០២៤ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទំនាក់ទំនងលេខ០៦០ ២១ ២១ ៨៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងយូរបំផុតត្រឹមថ្ងៃទី.០២.......ខែសីហា.ឆ្នាំ២០២៤ វេលាម៉ោង ៩:០០ព្រឹក...។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋានខាងលើ វេលាម៉ោង..០៩:០០ព្រឹក ថ្ងៃទី .០២...... ខែ .សីហា. ឆ្នាំ២០២៤។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ............ខែ..........ឆ្នាំរោង.....ឆស័ក ព.ស២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី......... ខែកក្កដា ឆ្នាំ២០២៤

ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម

អនុប្រធានទី១

គីម សុន

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ